01156615

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 10 / 2015
ម៉ោង (Time/Heure) : 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E319/7/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៥

**ផ្ញើជូន៖** ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីណែនាំដែលត្រូវបានកែសម្រួលស្តីពីការប្រើប្រាស់កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយពីសំណុំរឿង ០០៣ និង ០០៤

១. នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីបង្គាប់មួយស្តីពីការប្រើប្រាស់កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយពីសំណុំរឿង ០០៣ និង ០០៤ នៅក្នុងសវនាការ (ឯកសារ E319/7) "សេចក្តីបង្គាប់"។ អង្គជំនុំជម្រះសាលាដំបូងត្រូវបានជូនដំណឹងអំពីការរំលោភបំពានជាក់ស្តែងទៅលើសេចក្តីបង្គាប់ ជាពិសេសក្នុងអំឡុងពេលនៃកិច្ចដំណើការនីតិវិធីសវនាការនៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ (ឯកសារ E319/34)។

២. នៅក្នុងសេចក្តីបង្គាប់មានការណែនាំចំនួនប្រាំដាច់ពីគ្នា៖

(ក) ហាមឃាត់មិនឱ្យលើកយោង នៅក្នុងសវនាការជាសាធារណៈក្នុងសំណុំរឿង ០០២/០២ ទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយថាជាកំណត់ហេតុស្តាប់ចម្លើយដែលមានប្រភពពីសំណុំរឿង ០០៣ និង ០០៤

(ខ) ហាមឃាត់មិនឱ្យដាក់បង្ហាញដល់បុគ្គលណាម្នាក់ដែលមិនត្រូវបានអនុញ្ញាត នូវកំណត់ហេតុនៃការស្តាប់ចម្លើយដែលមានប្រភពពីសំណុំរឿង ០០៣ និង ០០៤ និងអត្តសញ្ញាណនៃកំណត់ហេតុទាំងនោះ តាមរយៈកាលបរិច្ឆេទ ឬការយោងទៅដល់សំណុំរឿងទាំងនោះ។

(គ) ហាមឃាត់មិនឱ្យបង្ហាញអត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយក្នុងសំណុំរឿង ០០៣ ឬ ០០៤ ជាសាធារណៈ។

(ឃ) តម្រូវឱ្យបង្ហាញអត្តសញ្ញាណរបស់សាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីពីសំណុំរឿង ០០៣ ឬ០០៤ តាមរយៈរហស្សនាម ឬ ពាក្យទូទៅប៉ុណ្ណោះ ក្នុងគោលបំណងដើម្បីបញ្ចៀសការបង្ហាញអត្តសញ្ញាណបុគ្គល។ និង

(ង) តម្រូវឱ្យបង្ហាញអត្តសញ្ញាណកំណត់ហេតុនៃការស្តាប់ចម្លើយរបស់បុគ្គលក្នុងសំណុំរឿង ០០៣ ឬ ០០៤ ត្រឹមតែថាជាកំណត់ហេតុពីមុនរបស់បុគ្គលនោះប៉ុណ្ណោះ។

៣. អង្គជំនុំជម្រះដឹងថា មានការលំបាកមួយចំនួនទាក់ទិននឹងការអនុវត្តសេចក្តីបង្គាប់នេះ និងពិចារណាឃើញថា សម្រាប់ពេលនេះ និងដរាបណានៅមានភាពចាំបាច់ក្នុងការការពារសុចរិតភាពនៃកិច្ចស៊ើបសួរ និងការការពារជនរងគ្រោះ និងសាក្សីដែលជាប់ពាក់ព័ន្ធ វិធីតែមួយគត់ដើម្បីធានាថាសេចក្តីបង្គាប់នេះត្រូវបានគោរពតាមយ៉ាងពេញលេញនោះ គឺត្រូវអនុវត្តដូចខាងក្រោម៖

(ក) នៅពេលស្តាប់សក្ខីកម្មសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ ឬ ០០៤ ការស្តាប់សក្ខីកម្មនោះត្រូវធ្វើឡើងក្នុងសវនាការជាសម្ងាត់ អនុលោមតាមវិធាន ៧៩(៦)(ខ) នៃវិធានផ្ទៃក្នុង។ ដោយកត់សម្គាល់ពីលក្ខខណ្ឌតម្រូវថា កិច្ចស៊ើបសួរត្រូវស្ថិតនៅជាសម្ងាត់(វិធាន៥៦(១) នៃវិធានផ្ទៃក្នុង) អង្គជំនុំជម្រះយល់ឃើញថា ការរំលោភបំពានលើភាពសម្ងាត់នេះអាចជាការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ (វិធាន ៣៥(ក) នៃវិធានផ្ទៃក្នុង) ដែលអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

(ខ) នៅពេលដែលភាគីណាមួយស្នើសុំសួរសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទាន់ត្រូវបានស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ ឬ ០០៤ ដោយប្រើប្រាស់កំណត់ហេតុពីសំណុំរឿងណាមួយក្នុងចំណោមសំណុំរឿងទាំងនោះ ភាគីត្រូវទុកសំណួរទាំងនោះរហូតដល់ចុងម៉ោងដែលផ្តល់ឱ្យពួកគេ។ បន្ទាប់មក ការស្តាប់សក្ខីកម្មនឹងធ្វើជាសម្ងាត់ក្នុងគោលបំណងដើម្បីសួរសំណួរទាំងនោះ ដោយផ្អែកលើកំណត់ហេតុទាំងនេះ។

៤. អង្គជំនុំជម្រះពិចារណាឃើញថា នីតិវិធីនេះនឹងអនុញ្ញាតឱ្យការស្តាប់សក្ខីកម្មប្រព្រឹត្តទៅដោយយុត្តិធម៌ ដោយពិចារណាទៅដល់ភ័ស្តុតាងពាក់ព័ន្ធទាំងអស់ ទន្ទឹមនឹងនោះក៏គោរពដល់ភាពសម្ងាត់នៃកិច្ចស៊ើបសួរដែលកំពុងបន្តដំណើរការផងដែរ។

៥. ចំពោះការរំលោភបំពានជាក់ស្តែងទៅលើសេចក្តីបង្គាប់ ក្នុងអំឡុងពេលសវនាការនៅថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានបង្គាប់ថា ព័ត៌មានសម្ងាត់ដែលបានបង្ហាញនៅក្នុងសវនាការជាសាធារណៈត្រូវតែកោសលុបចេញពីប្រតិចារឹកនៃសវនាការជាសាធារណៈ។ ភាគីត្រូវបានរម្លឹកថា ពួកគេនៅតែត្រូវអនុវត្តតាមសេចក្តីបង្គាប់ ក្នុងអំឡុងពេលសវនាការជាសាធារណៈ បន្ថែមទៅនឹងការអនុវត្តតាមសេចក្តីណែនាំបន្ថែមនេះ។